អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

អគ្គនាយកដ្ឋានស្រាវជ្រាវ

នាយកដ្ឋានស្រាវជ្រាវថវិកា

# ព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ច

## មាតិកា៖

- ការនាំចេញផលិតផលគ្រាប់ស្វាយចន្ទីរបស់កម្ពុជាទៅកាន់ទីផ្សារអន្តរជាតិបានកើនឡើងយ៉ាងខ្លាំង សម្រាប់រយៈពេល៤ខែដំបូងនៃឆ្នាំ២០២១
- កម្ពុជាអាចចៀសផុតពីការគំរាមកំហែង ដែលបង្កឡើងដោយការកើនឡើងដ៏ខ្លាំងនៃទំហំបំណុលសកល
- ប្រទេសកម្ពុជាបានចំណាយទឹកប្រាក់ប្រមាណ៣៣០លានដុល្លារ សម្រាប់ការនាំចូលជីកសិកម្មនៅក្នុងឆ្នាំ២០២០
- ចំណូលពន្ធលើពាណិជ្ជកម្មក្រៅប្រទេស ប្រចាំខែកុម្ភៈ ក្នុងឆ្នាំ២០២១
- ការធ្លាក់ចុះនៃសេដ្ឋកិច្ចប្រទេសថៃនៅក្នុងត្រីមាសទី១ មានការធូរស្រាល ប៉ុន្តែទស្សនវិស័យមួយចំនួន ត្រូវបានកាត់បន្ថយ ខណៈជំងឺកូវីដ-១៩ នៅតែអូសបន្លាយ
- សិង្ហបុរី និងហុងកុងពន្យារពេលការបើកព្រំដែនធ្វើដំណើរជាថ្មីម្តងទៀត ដោយសារមានករណីជំងឺកូវីដ-១៩ កើនឡើង
- អត្រាការប្រាក់លើបំណុលរបស់សហរដ្ឋអាមេរិក មានសភាពថេរនៅដើមសប្តាហ៍នេះ
- ការចាប់ផ្តើមអាជីវកម្មថ្មីនៅអាស៊ីអាគ្នេយ៍បង្ហាញនូវការកើនឡើងសក្តានុពលក្នុងការវិនិយោគ


ពិនិត្យ និងកែសម្រួលដោយ

- សួន ពុធថាវី អគ្គនាយិកា នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- គឹម សុចិត្រា អគ្គនាយករង នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- ណុប ចាន់ធី ប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា
- ម៉ែន ខែមរៈ អនុប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា

ចងក្រង និងបូកសរុបដោយ

- ធីម ប៊ុនធឿន ប្រធានការិយាល័យវិភាគចំណូល-ចំណាយ

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### ការនាំចេញផលិតផលគ្រាប់ស្វាយចន្ទីរបស់កម្ពុជា ទៅកាន់ទីផ្សារអន្តរជាតិ បានកើនឡើងយ៉ាងខ្លាំងសម្រាប់រយៈពេល ៤ខែដំបូងនៃឆ្នាំ២០២១



*ប្រភព៖ ខេមបូណ្ឌមីស ២០២១, រូបភាព៖ ចាន់ មង្គល*

យោងតាមរបាយការណ៍របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបង្ហាញថា ទំហំនៃការនាំចេញគ្រាប់ស្វាយចន្ទីរបស់កម្ពុជា មានការកើនឡើងយ៉ាងគំហុក ពីខែមករា ដល់ខែមេសា ឆ្នាំ២០២១ ដែលសម្រេចបានជិត ៧០ ម៉ឺនតោន ពោលគឺបានកើនឡើងប្រមាណជាង ២៧៣% ធៀបនឹងរយៈពេលដូចគ្នា ក្នុងឆ្នាំ២០២០។ ទន្ទឹមនេះ ប្រទេសដែលបាននាំចូលគ្រាប់ស្វាយចន្ទីរបស់កម្ពុជា រួមមាន ប្រទេសវៀតណាម ប្រទេសចិន ប្រទេសថៃ ប្រទេសជប៉ុន ប្រទេសឡាវ និងប្រទេសអារ៉ាប់។ ក្នុងនោះដែរ គេសង្កេតឃើញថា ប្រទេសវៀតណាមបានទិញស្វាយចន្ទីពីកម្ពុជា ក្នុងទំហំច្រើនជាងគេបង្អស់ ជិត៦៩ម៉ឺនតោន។ ជាក់ស្តែង គ្រាប់ស្វាយចន្ទីដែលត្រូវបាននាំចេញភាគច្រើន គឺជាផលិតផលដែលមិនទាន់កែច្នៃ។

ថ្វីបើ ការនាំចេញផលិតផលគ្រាប់ស្វាយចន្ទី មានការកើនឡើងគួរឱ្យកត់សម្គាល់ ក៏ប៉ុន្តែបើក្រឡេកមើលទៅលើទិន្នផលស្វាយចន្ទីវិញ បែរជាមានការធ្លាក់ចុះ ដោយសារឆ្នាំនេះ មានសន្សើមប្រៃ គួបផ្សំនឹងសត្វល្អិតនេះបើយោងតាមការអះអាងរបស់អ្នកជំនាញ។ បន្ថែមពីនេះ ម្ចាស់ចំការមួយចំនួនបានអះអាងថា ទិន្នផលបានធ្លាក់ចុះ ក្នុងចន្លោះពី ៣០% ទៅ ៥០%។

ដោយឡែក បើយោងតាមការបកស្រាយរបស់ប្រធានសមាគមស្វាយចន្ទីកម្ពុជា មូលហេតុដែលទំហំនៃការនាំចេញគ្រាប់ស្វាយចន្ទីបែរជាមានការកើនឡើង ស្របពេលដែលទិន្នផលបានធ្លាក់ចុះនោះ អាចបណ្តាលមកពីការកើនឡើងនៃផ្ទៃដីដាំដុះ និងការរីកចម្រើននៃបច្ចេកទេស ដាំដុះស្វាយចន្ទី៕ *ដោយ ជា សិរីរតន៍*

*ប្រភព៖ ខេមបូណ្ឌមីស ចេញផ្សាយ ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២១*

## កម្ពុជាអាចចៀសផុតពីការគំរាមកំហែង ដែលបង្កឡើងដោយការកើនឡើងដ៏ខ្លាំង នៃទំហំបំណុលសកល




*ប្រភព៖ IIF, Moody's Analytics ២០២១*

យោងតាមរបាយការណ៍វិភាគរបស់ក្រុមហ៊ុន Moody ប្រទេសកម្ពុជា ទំនងជាស្ថិតក្នុងស្ថានភាពល្អប្រសើរជាងប្រទេសដ៏ទៃទៀត ខណៈដែលកំណើនសេដ្ឋកិច្ចនៃប្រទេសជាច្រើននៅលើពិភពលោក អាចនឹងរងនូវផលប៉ះពាល់ពីអតិផរណា ដែលបង្កឡើងដោយកំណើននៃបំណុលសកល ដែលបានកើនប្រមាណជា ២៤ទ្រីលានដុល្លារ ក្នុងឆ្នាំ២០២០។

ទន្ទឹមនេះ របាយការណ៍នេះ ក៏បានលើកឡើងថា ថ្វីបើទស្សនវិស័យកំណើនសេដ្ឋកិច្ចចិន និងសហរដ្ឋអាមេរិកមានភាពល្អប្រសើរជាងមុន ប៉ុន្តែការកើនឡើងនៃបន្ទុកបំណុលជុំវិញពិភពលោក បានបង្កើនហានិភ័យចំពោះកំណើនសេដ្ឋកិច្ច និងស្ថិរភាពហិរញ្ញវត្ថុ ជាពិសេស ចំពោះប្រទេសដែលមានទីផ្សារកំពុងលូតលាស់ (Emerging markets) និងអឺរ៉ុបខាងត្បូង ដែលប្រទេសទាំងនេះមានការផ្ទុះឡើងខ្លាំង នូវរលកទី៣ និងទី៤ នៃវិបត្តិជំងឺកូវីដ-១៩។
ចំណែកឯប្រទេសកម្ពុជាវិញ ខណៈកំពុងទទួលរងគ្រោះនូវរលកទី២ នៃជំងឺកូវីដ-១៩ ផលប៉ះពាល់រយៈពេលមធ្យម និងវែង នៅមិនទាន់មានភាពច្បាស់លាស់។ ដោយឡែក យោងតាមសូចនាករថ្មីបំផុត បានបង្ហាញថា សេដ្ឋកិច្ចកម្ពុជា អាចមានភាពធន់(resilient) ប៉ុន្តែមានការចោទជាសំណួរជុំវិញការកើនឡើងនៃបំណុលរបស់អ្នកប្រើប្រាស់។

ការិយាល័យឥណទានកម្ពុជាបានបង្ហាញថា សមតុល្យនៃបំណុលអ្នកប្រើប្រាស់សរុប មានចំនួន១០,៣៩ប៊ីលានដុល្លារ ក្នុងត្រីមាសទី១ ឆ្នាំ២០២១ ដែលមានការកើនឡើង៦,៤៤% ពីត្រីមាសទី៤ ឆ្នាំ២០២០។ រីឯ បំណុលសរុបធៀបនឹងផ.ស.ស វិញ មានចំនួន២៨% ឬស្មើនឹង ៨,៨ប៊ីលានដុល្លារ សម្រាប់ឆ្នាំ២០២០ នេះបើយោងតាមអគ្គនាយកដ្ឋានកិច្ចសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល។

សូចនាករខាងលើនេះ អាចបង្ហាញថា ប្រទេសកម្ពុជាទំនងជាអាចនឹងមិនទទួលរងផលប៉ះពាល់ពីវិបត្តិសេដ្ឋកិច្ច (Economic shocks) និងហានិភ័យបំណុល ដែលបង្កឡើងពីការកើនឡើងខ្លាំង នៃបំណុលសកលនោះឡើយ៕

*ដោយ ជា សិរីរតន៍*

*ប្រភព៖ Khmer Times ចេញផ្សាយ ថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២១*

## ប្រទេសកម្ពុជាបានចំណាយទឹកប្រាក់ប្រមាណ ៣៣០លានដុល្លារ សម្រាប់ការនាំចូលជីកសិកម្មនៅក្នុងឆ្នាំ២០២០



*ប្រភព៖ post Khmer, 2021*

យោងតាមទិន្នន័យក្រសួងពាណិជ្ជកម្ម នៅក្នុងឆ្នាំ២០២០ ប្រទេសកម្ពុជាបាននាំចូលជីកសិកម្ម ថ្នាំសម្លាប់សត្វល្អិត និងស្មៅ សម្រាប់ប្រើប្រាស់ក្នុងវិស័យកសិកម្ម មានទឹកប្រាក់សរុបចំនួន ៣២៧,៩៧លានដុល្លារ កើនឡើង ១,២៥% បើធៀបនឹងឆ្នាំកន្លងទៅ ដែលមានទឹកប្រាក់ចំនួន ៣២៣,៥៤លានដុល្លារ។

លោក សុខ រ៉ាដែន ប្រធានសមាគមវារីវប្បករកម្ពុជា បានបង្ហាញថា កំណើនទិន្នផលក្នុងវិស័យកសិកម្ម រួមមានកសិផលវារីវប្បកម្ម និងផលិតកម្មសាច់សត្វ ជាកត្តាធ្វើឱ្យការនាំចូលថ្នាំសម្លាប់សត្វល្អិត និងជីកសិកម្មកើនឡើងជាបន្តបន្ទាប់។ គួរបញ្ជាក់ផងដែរ បច្ចុប្បន្នការនាំចូលផលិតផលសម្រាប់ធ្វើកសិកម្មទាំងអស់ ភាគច្រើនគឺធ្វើការនាំចូលពីប្រទេសជិតខាង។

ទន្ទឹមនឹងនេះ ដើម្បីលើកកម្ពស់ការយល់ដឹងអំពីការប្រើប្រាស់ថ្នាំកសិកម្ម និងជីកសិកម្មឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស នាយកដ្ឋាននីតិកម្មកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចុះផ្សព្វផ្សាយ និងណែនាំជាប្រចាំទៅដល់អាជ្ញាធរពាក់ព័ន្ធ អ្នកលក់ និងប្រជាកសិករអំពីគុណសម្បត្តិ និងគុណវិបត្តិនៃការប្រើប្រាស់ថ្នាំ និងជីកសិកម្ម។

ជារួម នៅក្នុងឆ្នាំ២០២០ តាមរបាយការណ៍របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានបង្ហាញថា ទិន្នន័យការនាំចេញផលិតផលកសិកម្មរបស់ប្រទេសកម្ពុជាមានតម្លៃសរុប ៤,៤ប៊ីលានដុល្លារ កើនលើសឆ្នាំមុនចំនួន ៥០០លានដុល្លារ៕ *ដោយ សេន ចន្ទូ*

*ប្រភព៖ postkhmer.com, ចេញផ្សាយថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២១*

## តារាងប្រចាំសប្តាហ៍៖ ចំណូលពន្ធលើពាណិជ្ជកម្មក្រៅប្រទេស ប្រចាំខែកុម្ភៈ ឆ្នាំ២០២១

តាមទិន្នន័យរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកម្ពុជា បង្ហាញថា នៅក្នុងខែកុម្ភៈឆ្នាំ២០២១នេះ រដ្ឋបាលថ្នាក់ជាតិប្រមូលចំណូលពន្ធលើពាណិជ្ជកម្មក្រៅប្រទេស បានចំនួនសរុប ១៥៣,១ប៊ីលានរៀល ដែលមានការធ្លាក់ចុះប្រមាណជា៤% ធៀបនឹងខែមករា។ ការធ្លាក់ចុះចំណូលនេះ ដោយសារការថមថយសកម្មភាពសេដ្ឋកិច្ចក្នុងបរិការណ៍រីករាលដាលជំងឺកូវីដ-១៩ នៅទូទាំងពិភពលោក។

ជាក់ស្តែង ការប្រមូលចំណូលពន្ធ និងអាករលើការនាំចេញ មានចំនួន ២,៣ប៊ីលានរៀល ដែលមានការធ្លាក់ចុះ ប្រមាណជា ១១% ធៀបនឹងខែមករា។

ដោយឡែក ចំណូលពន្ធ និងអាករលើការនាំចូលប្រមូលបានប្រមាណជា ១៥០,៨ប៊ីលានរៀល នៅក្នុងខែកុម្ភៈ ឆ្នាំ២០២១នេះ ដែលបានធ្លាក់ចុះប្រហែលជា៤% ធៀបនឹងខែមករា៕ *ដោយៈ មិត្ត ចន្ទី*

| បរិយាយ (គិតជាប៊ីលានរៀល) | មករា | កុម្ភៈ | កំណើន/ថយ(%) |
| --- | --- | --- | --- |
| ចំណូលពន្ធលើ ពាណិជ្ជកម្មក្រៅប្រ ទេស | 159.4 | 153.1 | -4.0% |
| ពន្ធ និងអាករលើ ការនាំចូល | 156.8 | 150.8 | -3.8% |
| ពន្ធ និងអាករលើ ការនាំចេញ | 2.64 | 2.35 | -11.0% |

*ប្រភពៈ*តារាងប្រតិបត្តិការហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

### ការធ្លាក់ចុះនៃសេដ្ឋកិច្ចប្រទេសថៃ នៅក្នុងត្រីមាសទី១ មានការធូរស្រាល ប៉ុន្តែទស្សនវិស័យមួយចំនួនត្រូវបានកាត់បន្ថយ ខណៈជំងឺកូវីដ-១៩ នៅតែអូសបន្លាយ



*ប្រភពៈ Bangkok Post, 2021 រូបភាពៈ Reuter file photo*

ការផ្ទុះឡើងនៃជំងឺកូវីដ-១៩ បានធ្វើឱ្យសេដ្ឋកិច្ច របស់ប្រទេសថៃធ្លាក់ចុះនៅក្នុងត្រីមាសទី១ ឆ្នាំ២០២១ ដោយសារការប៉ះពាល់ដល់ការប្រើប្រាស់ និងវិស័យទេសចរណ៍ ប៉ុន្តែការធ្លាក់ចុះនេះ គឺទាបជាងការរំពឹងទុក ដោយសារមានការកើនឡើងខ្លាំងនូវទិន្នផលមិនមែនកសិកម្ម និងការនាំចេញ។

យោងតាមទិន្នន័យពីក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គម(NESDC)បានបង្ហាញថា សេដ្ឋកិច្ចប្រទេសថៃបានធ្លាក់ចុះ២,៦% នៅក្នុងត្រីមាសទី១ ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន ដែលតួលេខនេះទាបជាងការព្យាករណ៍ដែលមានកម្រិតធ្លាក់ចុះ ៣,៣%។ បន្ថែមពីនេះ ការនាំចេញត្រូវបានរំពឹងថា នឹងមានការកើនឡើងដល់ ១០,៣% នៅក្នុងឆ្នាំ២០២១។ ចំណែកឯភ្ញៀវទេសចរណ៍បរទេសត្រូវបានព្យាករណ៍ថា នឹងមានប្រហែលកន្លះលាននាក់ នៅក្នុងឆ្នាំនេះ គឺទាបជាងការព្យាករណ៍ពីមុន ដែលមានចំនួន ៣,២លាននាក់។

ស្របគ្នានេះផងដែរ ទីភ្នាក់ងារផែនការបានបន្ទាបការព្យាករណ៍កំណើនសេដ្ឋកិច្ចរបស់ខ្លួនជាលើកទីពីរនៅឆ្នាំ២០២១នេះ ពី ២,៥% ទៅ ៣,៥% មកត្រឹម ១,៥% ទៅ ២,៥%វិញ ដោយសាររលកនៃជំងឺកូវីដ-១៩ នៅតែបន្តរហូតមកដល់ពេលនេះ។

ការផ្ទុះឡើងចុងក្រោយនៃរលកជំងឺឆ្លងថ្មីនេះបានចាប់ផ្តើមក្នុងខែមេសា និងមានចំនួនច្រើនជាង ២ភាគ៣ នៃការឆ្លងសរុបរបស់ប្រទេសថៃ ដែលបានកាត់បន្ថយសកម្មភាពសេដ្ឋកិច្ចក្នុងប្រទេស ស្របពេលដែល

ប្រទេសនេះមានដំណើរការចាក់វ៉ាក់សាំងយឺតយ៉ាវ និងកំពុងត្រៀមបើកដំណើរការជាថ្មីសម្រាប់ភ្ញៀវទេសចរបរទេស។

ដើម្បីជួយដល់ប្រជាជនក្នុងការទប់ទល់ ចំពោះការផ្ទុះឡើងនៃជំងឺកូវីដ-១៩ រាជរដ្ឋាភិបាលបានអនុម័តកញ្ចប់ថវិកាជំនួយបន្ថែម ដែលមានតម្លៃ ២៥៥ប៊ីលានបាត ព្រមទាំងបានដាក់ចេញនូវវិធានការផ្សេងៗ ដើម្បីជួយជំរុញដល់ការគាំទ្រសេដ្ឋកិច្ចរបស់ខ្លួនផងដែរ៕

*ដោយ មុំ ចិន្តា*

*ប្រភព៖ Bangkok Post, ចេញផ្សាយថ្ងៃទី១៧ ខែឧសភា ឆ្នាំ ២០២១*

## សិង្ហបុរី និងហុងកុងពន្យារពេលក្នុងការបើកព្រំដែនធ្វើដំណើរជាថ្មីម្តងទៀត ដោយសារមានករណីជំងឺកូវីដ-១៩ កើនឡើង




*ប្រភព ៖ CNBC, 2021 រូបភាព៖ Roslan Rahman*

ប្រទេសសិង្ហបុរី និងទីក្រុងហុងកុងបានពន្យារពេលនៃកិច្ចព្រមព្រៀងការចាប់ផ្តើមបើកព្រំដែនធ្វើដំណើរ (travel bubble) តាមដែនអាកាស ដែលពួកគេបានរំពឹងទុកជាយូរមកហើយនោះ។

ការបើកការធ្វើដំណើរនេះ នឹងមិនតម្រូវឱ្យអ្នកធ្វើដំណើរធ្វើចត្តាឡីស័កនោះទេ ដែលគ្រោងនឹងចាប់ផ្តើមនៅថ្ងៃទី ២៦ ខែឧសភា ខាងមុខនេះ។ នៅក្នុងកិច្ចព្រមព្រៀងនោះផងដែរ ការធ្វើដំណើរនេះនឹងត្រូវផ្អាក ប្រសិនបើចំនួនឆ្លងថ្មីនៃជំងឺកូវីដ-១៩ ក្នុងតំបន់នៃទីក្រុងទាំងពីរ លើសពី ៥ករណី ជាមធ្យមក្នុងរយៈពេល៧ថ្ងៃ។ ការអនុវត្តកិច្ចព្រមព្រៀងខាងលើនេះ ត្រូវបានពន្យារពេលជាច្រើនដងចាប់តាំងពីខែវិច្ឆិកា ឆ្នាំ២០២០មក។

ជាមួយគ្នានេះដែរ រដ្ឋាភិបាលហុងកុងបានលើកឡើងថា ការផ្តល់បច្ចុប្បន្នភាពនៃការធ្វើដំណើរតាមរយៈកិច្ចព្រមព្រៀងនេះ នឹងត្រូវប្រកាសឱ្យបានដឹងនៅមុន ឬនៅថ្ងៃទី១៣ ខែមិថុនា ខាងមុខនេះ។ គិតត្រឹមបច្ចុប្បន្ននេះ ចំនួនករណីឆ្លងកូវីដ-១៩ នៅទីក្រុងហុងកុង បានកើនឡើងរហូតដល់ ១១ ៨២៦នាក់ និងមានបាត់បង់ជីវិតចំនួន ២១០នាក់។

រីឯ ទិន្នន័យរបស់ក្រសួងសុខាភិបាលសិង្ហបុរីបានបង្ហាញថា នៅក្នុងរយៈពេលប៉ុន្មានថ្ងៃនេះករណីឆ្លងជំងឺកូវីដ-១៩ បានកើនឡើង ដែលធ្វើឱ្យចំនួនករណីឆ្លងសរុប នៃជំងឺនេះ កើនដល់ ៦១ ៦០០នាក់ និង៣១នាក់ បានស្លាប់។

ការកើនឡើងនៃជំងឺឆ្លងនៅក្នុងសហគមន៍ បានធ្វើឱ្យប្រទេសសឹង្ហបុរី មិនអាចបំពេញតាមលក្ខខណ្ឌ ក្នុងការចាប់ផ្តើមការបើកព្រំដែនធ្វើដំណើរតាមដែនអាកាសរបស់ខ្លួន នេះបើយោងតាមក្រសួងដឹកជញ្ជូនរបស់ប្រទេសសិង្ហបុរី។

ដើម្បីទប់ស្កាត់នូវករណីឆ្លងក្នុងស្រុក រដ្ឋាភិបាលសិង្ហបុរីបានដាក់វិធានការរឹតបន្តឹងមួយចំនួនរួមមាន៖ ការហាមឃាត់រាល់ការទទួលទានអាហារ និងភេសជ្ជៈ នៅតាមអាហារដ្ឋាន ការកំណត់ការជួបជុំសង្គមសាធារណៈ មិនឱ្យលើសពីមនុស្សពីរនាក់ ព្រមទាំងការបិទសាលារៀនភាគច្រើន និងប្តូរមកសិក្សាតាមប្រព័ន្ធអនឡាញជំនួសវិញ។

ប្រទេសសិង្ហបុរី និងទីក្រុងហុងកុង គឺជាមជ្ឈមណ្ឌលពាណិជ្ជកម្មដ៏ធំរបស់អាស៊ីដែលគ្មានការធ្វើដំណើរតាមជើងហោះហើរក្នុងស្រុកទេ។ ឧស្សាហកម្មផ្នែកទេសចរណ៍ និងអាកាសចរណ៍របស់ពួកគេពឹងផ្អែកទាំងស្រុងលើការធ្វើដំណើរជាអន្តរជាតិ ដែលត្រូវបានរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដោយជំងឺរាតត្បាតនេះ៕

*ដោយ មុំ ចិន្តា*

*ប្រភព៖ CNBC, ចេញផ្សាយថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២១*

## សេដ្ឋកិច្ចសកល

### អត្រាការប្រាក់លើបំណុលរបស់រដ្ឋាភិបាលសហរដ្ឋអាមេរិកមានសភាពថេរនៅដើមសប្តាហ៍នេះ




*ប្រភព៖ គេហទំព័រ CNBC, រូបភាព៖ CNBC NEWS*

អត្រាការប្រាក់លើប័ណ្ណបំណុលរបស់រដ្ឋាភិបាលសហរដ្ឋអាមេរិក សម្រាប់បំណុលរយៈពេល ១០ឆ្នាំ កើនឡើង ១,៦៤% ខណៈដែលអត្រាការប្រាក់សម្រាប់បំណុលរយៈពេល៣០ឆ្នាំ ធ្លាក់ចុះ ២,៣៥% ដែលឆ្លុះពីថ្លៃទំនិញ។ ទិន្នន័យកាលពីសប្តាហ៍មុនបង្ហាញថា សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (Consumer Price Index) កើនឡើងដល់ទៅ ៤,២% បើធៀបនឹងខែមេសាកាលពីឆ្នាំមុន ដែលជាអត្រាកំណើនលឿនបំផុត និងខ្ពស់ជាងការរំពឹងទុក គិតចាប់តាំងពីឆ្នាំ ២០០៨មក។ ធនាគារកណ្តាលរំពឹងថា អតិផរណារបស់សហរដ្ឋអាមេរិក នៅក្នុងឆ្នាំ ២០២១នេះ នឹងកើនឡើង ព្រោះតម្រូវការនៅក្នុងការធ្វើដំណើរ ការហូបចុក និងតម្រូវការសេវា និងទំនិញចាប់ផ្តើមមានកំណើនឡើងវិញ បន្ទាប់ពីវិបត្តិដោយសារវិបត្តិជំងឺកូវីដ-១៩។ ទោះយ៉ាងណា មន្ត្រីរបស់ធនាគារកណ្តាលសហរដ្ឋអាមេរិកបាននិយាយថា នេះគ្រាន់តែជាការកើនឡើងបណ្តោះអាសន្នប៉ុណ្ណោះ ហើយរំពឹងថានឹងធ្លាក់ចុះមក ២% ជាមធ្យម ដែលជាគោលដៅថ្មី។ ធនាគារកណ្តាលមានគោលបំណងជំរុញឱ្យអតិផរណាកើនឡើងខ្ពស់ជាង ២% ក្នុងរយៈពេលខ្លះ ដើម្បីទូទាត់ជាមួយនឹងរយៈពេលដែលមានអត្រាទាបមុនពេលខ្លួនធ្វើការផ្លាស់ប្តូរគោលនយោបាយរូបិយវត្ថុ៕

*ដោយ វង្ស ច័ន្ទស៊ើដារា*

*ប្រភព៖ គេហទំព័រ CNBC, ចេញផ្សាយថ្ងៃទី១៧ ខែឧសភា ឆ្នាំ ២០២១*

## ការចាប់ផ្តើមអាជីវកម្មថ្មីនៅអាស៊ីអាគ្នេយ៍បង្ហាញនូវការកើនឡើងនូវសក្តានុពលក្នុងការវិនិយោគ



*ប្រភព៖ គេហទំព័រ CNBC, រូបភាព៖ VERVE TIMES NEWS*

យោងតាមក្រុមហ៊ុនមូលធនឈានមុខមួយ ក្នុងចំណោមក្រុមហ៊ុនមូលធនឈានមុខជាច្រើនបង្ហាញថា ការចាប់ផ្តើមអាជីវកម្មថ្មី នៅតំបន់អាស៊ីអាគ្នេយ៍ធ្វើឱ្យមានការកើនឡើងនូវសក្តានុពលក្នុងការវិនិយោគ នៅពេលដែលជំងឺរាតត្បាតសាកលបានផ្លាស់ប្តូរនូវកំលាំងចលករ នៃកំណើនសេដ្ឋកិច្ចជាច្រើនក្នុងរយៈពេលវែង។ ថ្វីត្បិតតែផលប៉ះពាល់នេះ មានភាពធ្ងន់ធ្ងរ ប៉ុន្តែការធ្លាក់ចុះនេះក៏បានផ្តល់នូវឱកាសដល់ការចាប់ផ្តើមអាជីវកម្មថ្មីនៅក្នុងតំបន់។ លោក Roderick Purwana ដៃគូគ្រប់គ្រងនៅ East Ventures ដែលមានទីតាំងនៅឥណ្ឌូនេស៊ីបាននិយាយថា អាជីវកម្មថ្មីៗជាច្រើនត្រូវបានបង្កើតឡើងក្នុងអំលុងពេលនេះ ជាពិសេស អាជីវកម្មផ្នែកឌីជីថលដូចជា បច្ចេកវិទ្យាក្នុងការអប់រំ បច្ចេកវិទ្យាផ្នែកសុខាភិបាល និងបច្ចេកវិទ្យាហិរញ្ញវត្ថុ។ លោកបានមានប្រសាសន៍យ៉ាងដូច្នេះថា «វិបត្តិនីមួយៗតែងតែ នាំមកនូវឱកាសថ្មីជានិច្ច»។ នៅប្រទេសឥណ្ឌូនេស៊ី ក្រុមហ៊ុនដឹកជញ្ជូនអ្នកដំណើរខ្នាតធំ Gojek បានប្រកាសថា ខ្លួនបានរួមជាមួយក្រុមហ៊ុន Tokopedia ដែលជាក្រុមហ៊ុនពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក (e-commerce) ដើម្បីបង្កើតក្រុមហ៊ុន GoTo Group ដែលមានតម្លៃប្រមាណពី ៣៥ ទៅ ៤០ប៊ីលានដុល្លារ។

លើសពីនោះ ក្រុមហ៊ុនផ្សារភាគហ៊ុន (SPACs)ជាច្រើនបានរីកដុះដាលទាំងនៅក្នុងតំបន់ និងពិភពលោក។ កាលពីខែមុន ក្រុមហ៊ុនយក្ស Grab បានប្រកាសអំពីការវិនិយោគលើផ្សារភាគហ៊ុនរួមគ្នាជាមួយក្រុមហ៊ុន Nasdaq ក្នុងតម្លៃប្រហែល ជិត ៤០ប៊ីលាន។ លោក Roderick Purwana បានបន្ថែមទៀតថា SPACs គឺជាឱកាសសម្រាប់ក្រុមហ៊ុនបច្ចេកវិទ្យានៅក្នុងការទាក់ទាញទីផ្សារភាគហ៊ុននៅសហរដ្ឋអាមេរិក ផងដែរ៕

*ដោយ វង្ស ច័ន្ទស្មើដារា*

*ប្រភព៖ គេហទំព័រ CNBC, ចេញផ្សាយថ្ងៃទី១៧ ខែឧសភា ឆ្នាំ ២០២១*

## ទិន្នន័យស្រាវជ្រាវសម្រាប់សប្តាហ៍បន្ទាប់

ទិន្នន័យសម្រាប់សប្តាហ៍ខាងមុខនេះ រួមមាន៖ សន្ទស្សន៍សកម្មភាពជាតិនៃធនាគារឈីកាហ្គោ និងការលក់ផ្ទះថ្មីនៅសហរដ្ឋអាមេរិក ការលក់ទំនិញរាយរបស់ប្រទេសរុស្ស៊ី ការលក់ផលិតផលឧស្សាហកម្ម និងតុល្យភាពថវិការបស់ប្រទេសកាណាដា ទំនុកចិត្តអាជីវកម្មនៅប្រទេសកូរ៉េខាងត្បូង សូចនាករបរិយាកាសអាជីវកម្មនៅប្រទេសបារាំង ប្រាក់ចំណេញឧស្សាហកម្មរបស់ប្រទេសចិន

ការចំណាយមូលធនឯកជនរបស់ប្រទេសអូស្ត្រាលី និងទស្សនៈសេដ្ឋកិច្ចនៅតំបន់ចាយប្រាក់អឺរ៉ូ៕

ខាងក្រោម គឺជាប្រតិទិនដែលនាយកដ្ឋានស្រាវជ្រាវថវិកានឹងបន្តតាមដាននៅសប្តាហ៍ក្រោយៈ

ថ្ងៃចន្ទ ទី២៤ ខែឧសភា ឆ្នាំ២០២១

- សន្ទស្សន៍សកម្មភាពជាតិនៃធនាគារឈីកាហ្គោនៅសហរដ្ឋអាមេរិក សម្រាប់ខែមេសា
- ការលក់ទំនិញរាយរបស់ប្រទេសរុស្ស៊ី ធៀបនឹងឆ្នាំមុន សម្រាប់ខែមេសា

ថ្ងៃអង្គារ ទី២៥ ខែឧសភា ឆ្នាំ២០២១

- ការលក់ផលិតផលឧស្សាហកម្មរបស់ប្រទេសកាណាដា ធៀបនឹងខែមុន សម្រាប់ខែមេសា
- ការលក់ផ្ទះថ្មីនៅសហរដ្ឋអាមេរិក សម្រាប់ខែមេសា

ថ្ងៃពុធ ទី២៦ ខែឧសភា ឆ្នាំ២០២១

- ទំនុកចិត្តអាជីវកម្មនៅប្រទេសកូរ៉េខាងត្បូង សម្រាប់ខែឧសភា
- សូចនាករបរិយាកាសអាជីវកម្មនៅប្រទេសបារាំង សម្រាប់ខែឧសភា

ថ្ងៃព្រហស្បតិ៍ ទី២៧ ខែឧសភា ឆ្នាំ២០២១

- ប្រាក់ចំណេញឧស្សាហកម្មរបស់ប្រទេសចិន ធៀបនឹងឆ្នាំមុន សម្រាប់ខែមេសា
- ការចំណាយមូលធនឯកជនរបស់ប្រទេសអូស្ត្រាលី ធៀបនឹងត្រីមាសមុន សម្រាប់ត្រីមាសទី១

ថ្ងៃសុក្រ ទី២៨ ខែឧសភា ឆ្នាំ២០២១

- តុល្យភាពថវិការបស់ប្រទេសកាណាដា សម្រាប់ខែមីនា
- ទស្សនៈសេដ្ឋកិច្ចនៅតំបន់ចាយប្រាក់អឺរ៉ូ សម្រាប់ខែឧសភា